# ចំណេះដឹងខ្លះដែលយើងគួរស្វែងយល់និងគួរដឹង

## អ្វីគឺសាសនា?

សាសនា តាមប្រភពដើមនៃពាក្យនេះមានន័យថា ពាក្យប្រៀនប្រដៅ។ តែតាមទស្សនៈរបស់ពួកបច្ចឹមប្រទេសគេហៅថារីលីជិន(Religion) ដែលមានន័យដោយឫសនៃពាក្យថា ការបូជាខ្លួនចំពោះអាទិទេព្យ(god or creator) ។

ដូច្នេះយើងអាចដឹងថា ឥទ្ធិពលនៃអាទិទេព្យនេះមានភាពខ្លាំងក្លាណាស់សំរាប់មនុស្សជាតិយើងចាប់តាំងពីអតីតជាតិមកទល់បច្ចុប្បន្ន។ ហើយពួកអឺរ៉ុបមានមូលដ្ឋានជឿទៅលើអាទិទេពដោយមានការវិវឌ្ឍន៍មកច្រើនយុគច្រើនសម័យ។

ខ្មែរយើងមានទស្សនៈតថភាពនិយម(empiricism)ថា ជំនឿលើអាទិទេពគឺជាជំនឿអរូបីយ៍ដឹកនាំមនុស្សទៅរកភាពឆ្កួតវង្វេងវង្វាន់។ តាំងពីបុរាណកាលមកខ្មែរយើងមិនជឿទៅលើអាទិទេពទេ ពួកគេជឿទៅលើខ្លួនឯង ដោយមានប្រមុខល្អដូចជា **ដូន** និង **តា** ជាអ្នកដឹកនាំ។ ជាក់ស្តែងខ្មែរយើងមានសាសនារបស់ខ្លួនដែលគេហៅថា **សាសនាដូនតា**។ សព្វថ្ងៃនេះពួកបច្ចឹមប្រទេសក៏ត្រឡប់មកជឿលើខ្លួនឯងបែបតថភាពនិយមនេះដែរ ។

សំរាប់ព្រះពុទ្ធសាសនា គឺមានន័យថាការខិតខំប្រព្រឹត្តនិងជឿតាមពាក្យប្រៀនប្រដៅរបស់អ្នកត្រាស់ដឹងទ្រង់ព្រះនាមថា **ព្រះពុទ្ធ**។ ការប្រព្រឹត្តនិងជឿតាមនេះមានន័យថា គោលដៅជីវិតមានសេចក្តីសុខ ឋានសួគ៌ា និងព្រះនិព្វានគឺមានពិតប្រាកដ។ ប៉ុន្តែសេចក្តីសុខ ឋានសួគ៌ា និងព្រះនិព្វាននេះមិនដែលមកអូសទាញដៃយើងទេ មានតែយើងផ្ទាល់ដែលជាអ្នកខិតខំប្រឹងប្រែងតាមត្រីវិស័យមួយដែលត្រឹមត្រូវ ដូចជាផែនទីដែលអ្នកធ្វើដំណើរត្រូវប្រើប្រាស់ដើម្បីទៅដល់គោលដៅ។ ព្រះពុទ្ធជាម្ចាស់គឺជា**អាតាខារោ** មានន័យថាជាអ្នករកឃើញគោលដៅគឺសេចក្តីសុខ ឋានសួគ៌ា និងព្រះនិព្វាន រួចព្រះអង្គបានគូសវាសផែនទីទុកឱ្យយើងទាំងឡាយប្រើប្រាស់ប្រកបដោយការយកចិត្តទុកដាក់ និងការព្យាយាម។

# គោលដៅរបស់សាសនាគ្រប់សាសនា

បើនិយាយតាមភាសារបស់បុថុជ្ជន ឬសាមញ្ញជនធម្មតា គោលដៅរបស់សាសនាជាទូទៅ គឺដើម្បីស្វែងរកសេចក្តីស្កប់ស្កល់នៅក្នុងចិត្ត(Emotional comfort)។ ដូច្នេះហើយបានជាយើងឃើញមនុស្សទាំងឡាយគោរពជឿទៅលើសាសនាផ្សេងៗរបស់ខ្លួនដូចជា ព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនា យិវ អ៊ីស្លាម គ្រីស្តសាសនា សាសនាស៊ិក ឬសាសនាស្ញូរ៉ូអាស្ទើរជាដើម ។

បើមនុស្សគ្មានសេចក្តីស្កប់ស្កល់ចិត្ត(Emotional comfort)ទេ គេមិនទៅជឿលើសាសនាទេ។ សព្វថ្ងៃសេចក្តីស្កប់ស្កល់ចិត្តក៏អាចកើតមានចំពោះអ្នកមិនជឿសាសនាដែរ ដោយពួកគេទាំងអស់នោះមានសេចក្តីសុខចំពោះអំពើល្អដែលគេធ្វើ ព្រមទាំងសមាធិចិត្តដែលគេមាន។

សេចក្តីស្កប់ស្កល់ចិត្តនេះអាចមានឡើងតាមរយៈជំនឿស៊ុបក្នុងខួរក្បាល(faith or extreme faith)របស់ពួកគេ ការអធិដ្ឋានបួងសួង(praying) និងការធ្វើអំពើល្អ(good deed)។

បុគ្គលដែលគេព្យាយាមទៅបួងសួងរៀងរាល់ថ្ងៃសៅរ៍ឬថ្ងៃអាទិត្យនៅក្នុងវិហារគ្រីស្តឬក៏វិហារអ៊ីស្លាម ព្រោះតែនាយគង្វាលរបស់គេចេះនិយាយលួងលោម និងទាក់ទាញឱ្យក្រុមជុំនំទាំងនោះទទួលបាននូវសេចក្តីស្ងប់ និងការស្កប់ស្កល់ក្នុងចិត្ត ។

សាសនាណាក៏ដោយ បើមិនអាចស្វែងរក ឬផ្តល់ឱ្យនូវសេចក្តីស្កប់ស្កល់ក្នុងចិត្តឱ្យដល់ក្រុមជុំនំរបស់ខ្លួនទេ សាវ័ករបស់គេអាចនឹងត្រូវថយចុះ ។

ដូច្នេះតើព្រះសង្ឃខ្មែរយើងនៅគ្រប់វត្តវ៉ាអារាម មានសេចក្តីយល់ដឹងខាងចិត្តវិទ្យា និងវិធីសាស្រ្តវិទ្យាក្នុងការពន្យល់ ទេសនា ឬការណែនាំឱ្យពុទ្ធបរិស័ទបានទទួលនូវសេចក្តីស្ងប់ សេចក្តីស្កប់ស្កល់ក្នុងចិត្ត និងបញ្ញាបានខ្លះហើយនៅ?

ព្រះពុទ្ធសាសនា មានខ្លឹមធម៌ជ្រាលជ្រៅជាងសាសនាដទៃឆ្ងាយណាស់។ ព្រះពុទ្ធអង្គត្រាស់ថា **នត្ថិ សន្តិ បរំ សុខំ និព្វានំ បរមំ សុខំ** មានន័យថា **គ្មានសេចក្តីសុខណាស្មើនឹងសេចក្តីស្ងប់ ព្រះនិព្វានជាបរមសុខ**។

សេចក្តីស្កប់ស្កល់ចិត្ត(Emotional comfort) គឺសេចក្តីស្ងប់នោះឯងហើយ។ សេចក្តីស្ងប់នៅក្នុងព្រះពុទ្ធសាសនានេះ មិនមែនស្ងប់ដែលកើតចេញតែពីការបួងសួង អង្វរករ ឬការជឿជាក់នោះទេ។

ការដែលញាតិញោមមកវត្ត ថ្វាយបង្គំព្រះ អុចធូបទៀន ថ្វាយផ្កាភ្ញី **នាំឱ្យចិត្តស្ងប់**

ការដែលញាតិញោមសូត្រធម៌ នមស្ការព្រះរតនត្រ័យជាប្រចាំ **នាំឱ្យចិត្តស្ងប់**

ការដែលញាតិញោមជួបព្រះសង្ឃ ហើយបានសំណេះសំណាលធម៌អាថ៌ **នាំឱ្យចិត្តស្ងប់**

ការដែលញាតិញោមធ្វើទាន ប្រគេនចង្ហាន់ដល់ព្រះសង្ឃ **នាំឱ្យចិត្តស្ងប់**

ការដែលញាតិញោមរក្សាសីល សង្រួមកាយ វាចា **នាំឱ្យចិត្តស្ងប់**

ការដែលញាតិញោមចំរើនភាវនាវ អប់រំចិត្ត **នាំឱ្យចិត្តស្ងប់**

យើងឃើញថា សកម្មភាពទាំងអស់ដែលមនុស្សយកសាសនាជាទីពឹងនេះ គឺដើម្បីឱ្យមានភាពស្កប់ស្កល់និងទីពឹងផ្លូវចិត្តនោះឯង ។

ព្រះពុទ្ធជាម្ចាស់មិនមែនអប់រំយើងឱ្យចិត្តស្ងប់ស្ងល់ធម្មតាៗតាមរយៈការសូត្រធម៌ ការបួងសួង ឬការធ្វើទានតែម្យ៉ាងប៉ុណ្ណោះទេ គឺព្រះអង្គណែនាំយើងឱ្យធ្វើសមាធិចិត្តមានសមថសមាធិ និងវិបស្សនាសមាធិ ។ ការបដិបត្តិសមាធិមានកំរិតនៃការសំរេចធម៌ច្រើនលំដាប់ដូចជា ឧបចារៈ បីតិ សុខៈ បស្សទ្ធិ ឯកកគ្គារម្មណ៍ រហូតដល់បានសំរេចបឋមឈាន ទុតិយឈាន តតិយឈាន និតចតុតឈានជាដើម ។

## តើសាសនាទាំងអស់សុទ្ធតែល្អដូចៗគ្នាដែរឬទេ?

មានពាក្យនិយាយតៗគ្នាថា គ្រប់សាសនាទាំងអស់សុទ្ធតែបង្រៀនឱ្យមនុស្សល្អ ។ បើនិយាយតាមការមិនគិតពិចារណា ពាក្យនេះអាចជាការពិតត្រឹមត្រូវ ។ តែបើនិយាយតាមពាក្យពិតគឺវាដូចជាសម្លម្ជូយឆ្នាំងដូចគ្នា តែអ្នកស្លខុសគ្នានឹងមិនអាចធ្វើឱ្យសម្លនេះមានរសជាតិដូចគ្នាបានឡើយ ។ ពិតណាស់ហើយថាវាជាសម្លម្ជូដូចគ្នា តែពិតជាមានរសជាតិខុសគ្នាដាច់ខាត ។ ទាំងព្រះពុទ្ធ ទាំងព្រះយេស៊ូ ទាំងព្រះម៉ូហាម៉ាត់ ឬម៉ូសេសជាដើម សុទ្ធតែមានប្រភពនៃចំណេះដឹងនិងការបង្កើតស្ថាប័នសាសនាខុសៗគ្នា ។

ព្រះពុទ្ធជាម្ចាស់គឺជាអ្នកត្រាស់ដឹង ដែលការត្រាស់ដឹងនេះកើតពីការពិសោធន៍របស់ព្រះអង្គនិងការព្យាយាមពិតប្រាកដ ។ ព្រះអង្គបានពិសោធន៍ជីវិតជាក្សត្រនៅក្នុងព្រះរាជវាំង និងពិសោធន៍ជីវិតជាអ្នកធ្វើតបៈធម៌ដ៏តឹងតែងជាងគេបង្អស់ ។ ក្រោយមកព្រះអង្គបានរកឃើញនូវផ្លូវកណ្តាលដែល

ជាមាគ៌ានាំទៅរកការរលត់នូវទុក្ខគ្រប់បែបយ៉ាង ។ ព្រះធម៌ទាំង៨៤០០០ព្រះធម្មក្ខន្ធរបស់ព្រះអង្គមានអាយុមក២៥៥០ឆ្នាំ នៅតែអាចពិសោធន៍បាន និងបដិបត្តិបានប្រយោជន៍ពិតជាក់ស្តែង ។

ធម៌ពិតរបស់ព្រះអង្គដែលមានលក្ខណៈពិសេសជាងគេ គឺអាចកាត់សេចក្តីធម៌វិន័យបានតាមលក្ខណៈ៨ប្រការគឺ ១-វិរាគាយៈ ប្រព្រឹត្តទៅដើម្បីអស់នូវតម្រេក, ២-វិសំយោគាយៈ ប្រព្រឹត្តទៅដើម្បីប្រាសចាកទុក្ខ, ៣-អបចយាយៈ ប្រព្រឹត្តទៅដើម្បីមិនសន្សំកិលេស,៤-អប្បិច្ឆតាយៈ ប្រព្រឹត្តដើម្បីប្រាថ្នាតិច, ៥-សន្តុដ្ឋិយា ប្រព្រឹត្តទៅដើម្បីសេចក្តីត្រេកអរចំពោះវត្ថុតាមមានតាមបាន, ៦-បវិវេកាយៈ ប្រព្រឹត្តទៅស្ងាត់ចាកក្រុមគណៈ, ៧-វិរិយារម្ភាយៈ ប្រព្រឹត្តដើម្បីប្រារព្ធសេចក្តីព្យាយាម, ៨-សុភរតាយៈ ប្រព្រឹត្តទៅដើម្បីគេចិញ្ចឹមងាយ ។

សាសនាដទៃច្បាស់ជាមិនអាចរកគោលការណ៍នៃការកាត់សេចក្តីបទដ្ឋានល្អអាក្រក់សំរាប់សាសនារបស់គេដូច្នេះបានឡើយ ។